# នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង
# អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

## ព័ត៌មានពិស្តារអំពីការដាក់ឯកសារ

សំណុំរឿងលេខ: ០០២/១៩-០៩-២០០៧-អ.វ.ត.ក-អ.ជ.ស.ជ

ភាគីដាក់ឯកសារ: ក្រុមមេធាវីការពារក្តីលោក នួន ជា

ដាក់ជូន: អង្គជំនុំជម្រះសាលាដំបូង

ភាសាដើម: អង់គ្លេស

កាលបរិច្ឆេទឯកសារ: ថ្ងៃទី ១២ ខែ កក្កដា ឆ្នាំ ២០១២

ឯកសារបកប្រែ
TRANSLATION/TRADUCTION
ថ្ងៃ ខែ ឆ្នាំ (Date): 12-Jul-2012, 13:15
CMS/CFO: Sann Rada

## ចំណាត់ថ្នាក់ឯកសារ

ចំណាត់ថ្នាក់ឯកសារ ស្នើឡើងដោយភាគីដាក់ឯកសារ: សាធារណៈ

ចំណាត់ថ្នាក់ឯកសារដោយ កសចស ឬ អង្គជំនុំជម្រះ សាធារណៈ/Public

ពិនិត្យឡើងវិញចំពោះឯកសារចំណាត់ថ្នាក់បណ្តោះ

អាសន្ន:

ឈ្មោះមន្ត្រីកត់ត្រា:

ហត្ថលេខា:

---

# សំណើវិធាន ៨៧ សុំប្រើប្រាស់ឯកសារក្នុងអំឡុងពេលសួរដេញដោលអ្នកជំនាញ DAVID CHANDLER

---

<u>ដាក់ដោយ</u>៖

**ក្រុមមេធាវីការពារក្តី នួន ជា**

សុន អរុណ

Michiel PESTMAN
Victor KOPPE
Andrew IANUZZI
Jasper PAUW

ព្រុំ ផល្លា

Scarlett WANGER
Devika KAMP

<u>ផ្ញើជូន</u>៖

**សហព្រះរាជអាជ្ញា**

លោកស្រី ជា លាង

លោក Andrew CAYLEY

**ក្រុមមេធាវីការពារក្តីទាំងអស់**

## I. សេចក្តីផ្តើម

១. អនុលោមតាមវិធាន ៨៧(៣) និង (៤) នៃវិធានផ្ទៃក្នុងរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ("វិធានផ្ទៃក្នុង") មេធាវីការពារក្តីជនជាប់ចោទ នួន ជា ("ក្រុមមេធាវីការពារក្តី") តទៅនេះសូមដាក់សំណើនេះ ("សំណើ") សុំប្រើប្រាស់ឯកសារជាក់លាក់ ដើម្បីធ្វើតេស្តពីភាពគួរឱ្យជឿជាក់បាននៃសាក្សីអ្នកជំនាញសាស្ត្រាចារ្យ David Chandler។ បញ្ជីនៃឯកសារទាំងនេះ ដាក់ភ្ជាប់មកជាមួយជាឧបសម្ព័ន្ធ **ក** ។

២. ក្រុមមេធាវីការពារក្តីបញ្ជាក់ឡើងវិញពីជំហរដ៏រឹងមាំរបស់ខ្លួនថាវិធាន៨៧ មិនអាចយកមកអនុវត្តបានទេចំពោះឯកសារ ដែលត្រូវប្រើប្រាស់តែសម្រាប់គោលបំណងនៃការជជីកសួរដេញដោលសាក្សី ហើយក៏មិនមានបំណងដាក់នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូងសម្រាប់ការបញ្ជាក់ពីភាពត្រឹមត្រូវនៃខ្លឹមសាររបស់វាដែរ ។ ទាក់ទងនឹងចំនុចនេះ មេធាវីការពារក្តីសូមដាក់បញ្ចូលសារណានានាដែលមាននៅក្នុងសំណើជាលាយលក្ខណ៍អក្សរ និងដោយផ្ទាល់មាត់លើកមុនរបស់ខ្លួន[1]។ តបតាមការសម្រេចពីលើកមុនរបស់អង្គជំនុំជម្រះ[2] ក្រុមមេធាវីការពារក្តី មិនមានជម្រើសអ្វីទេ តែត្រូវដាក់សំណើនេះដោយអនុលោមតាមវិធាន ៨៧។ ប៉ុន្តែក្រុមមេធាវីស្នើសុំឱ្យពិចារណាថា ការអនុវត្តឱ្យបានត្រឹមត្រូវនិងសមហេតុផលនៃវិធាន៨៧នេះ ទាមទារឱ្យមានការបកស្រាយឱ្យបានទូលំទូលាយនៃលក្ខខណ្ឌតម្រូវសម្រាប់ការទទួលយករបស់វិធាននេះ។ ការបកស្រាយបែបនេះ ត្រូវបានគាំទ្រដោយខ្លឹមសារយ៉ាងច្បាស់លាស់របស់វិធាននេះ និងគោលបំណង និងបរិបទរបស់វា ព្រមទាំងតថភាពជាក់ស្តែងនៃការជំនុំជម្រះដែលមានចំពោះមុខអង្គជំនុំជម្រះ។

---

[1] ឯកសារលេខ **E-206** "ការជូនដំណឹងពីការដាក់ឯកសារសម្រាប់ការជជីកសួរដេញដោលសាក្សី TCW 487" ថ្ងៃទី ២៨ ខែ ឧសភា ឆ្នាំ ២០១២, ERN 00811080-00811083 កថាខណ្ឌ ១ ដល់ ២។ ឯកសារលេខ **E-206** "ឧបសម្ព័ន្ធ ខ សារណាលើកមុនរបស់មេធាវីការពារក្តីអំពីការដាក់ឯកសារដេញដោលសាក្សី" ថ្ងៃទី ២៨ ខែ ឧសភា ឆ្នាំ២០១២, ERN 00812802-00812805 ។

[2] ឯកសារលេខ **E-199** "អនុស្សរណៈជូនភាគីទាំងអស់ក្នុងសំណុំរឿង ០០២ "សេចក្តីណែនាំពាក់ព័ន្ធនឹងឯកសារដែលភាគីស្នើសុំដាក់ចំពោះមុខអង្គជំនុំជម្រះ សម្រាប់គោលបំណងនៃការសួរផ្តេញ" ថ្ងៃទី ២៤ ខែ ឧសភា ឆ្នាំ ២០១២, ERN 00809908។

## II. ច្បាប់ពាក់ព័ន្ធ

៣. វិធាន៨៧(១) នៃវិធានផ្ទៃក្នុង ចែងត្រង់ផ្នែកពាក់ព័ន្ធថា"លើកលែងតែមានបទបញ្ញត្តិផ្សេងក្នុងវិធានផ្ទៃក្នុងនេះ រាល់ភស្តុតាងទាំងអស់ត្រូវតែទទួលយក"។

៤. វិធាន៨៧(២) ចែងត្រង់ផ្នែកពាក់ព័ន្ធថា "សេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងត្រូវផ្អែកលើភស្តុតាងដែលបានដាក់នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង ហើយភស្តុតាងនោះត្រូវឆ្លងកាត់ការដេញដោល"។

៥. វិធាន៨៧(៣) ចែងត្រង់ផ្នែកពាក់ព័ន្ធថា៖

ភស្តុតាងដែលមាននៅក្នុងសំណុំរឿង ត្រូវបានចាត់ទុកថាបានលើកឡើងនៅចំពោះមុខអង្គជំនុំជម្រះ ឬភាគី បើសិនជាខ្លឹមសាររបស់វាត្រូវបានសង្ខេប ត្រូវបានអាន ឬត្រូវបានកំណត់បង្ហាញអត្តសញ្ញាណយ៉ាងសមស្របក្នុងសវនាការ។
អង្គជំនុំជម្រះសាលាដំបូងអាចបដិសេធចំពោះពាក្យសុំពិនិត្យភស្តុតាងបើយល់ឃើញថា៖

ក. មិនជាប់ពាក់ព័ន្ធ ឬជាការស្នើសុំជាន់គ្នា

ខ. មិនអាចរកបានក្នុងរយៈសមស្របណាមួយ

គ.មិនសមស្របសម្រាប់បញ្ជាក់អង្គហេតុដែលជាគោលដៅនៃការស្នើសុំពិនិត្យភស្តុតាង

ឃ.ច្បាប់មិនអនុញ្ញាត ឬ

ង. មានចេតនាពន្យាកិច្ចដំណើរការនីតិវិធី ឬគ្មានប្រយោជន៍។

៦. វិធាន៨៧(៤) ចែងត្រង់ផ្នែកពាក់ព័ន្ធថា៖

ក្នុងអំឡុងពេលសវនាការ...អង្គជំនុំជម្រះអាចកោះហៅ ឬស្តាប់ចម្លើយបុគ្គលណាម្នាក់ក្នុងឋានៈជាសាក្សី ឬទទួលនូវភស្តុតាងថ្មីដែលមានប្រយោជន៍សម្រាប់នាំមកនូវការស្វែងរកការពិត... អង្គជំនុំជម្រះនឹងធ្វើសេចក្តីសម្រេចចំពោះការស្នើសុំនោះផ្អែកតាមខ្លឹមសារដែលមានចែងក្នុងវិធាន៨៧(៣) ខាងលើ។ ភាគីដែលស្នើសុំត្រូវតែធ្វើឱ្យអង្គជំនុំជម្រះជឿថាសក្ខីកម្ម ឬវត្ថុតាងដែលបានស្នើសុំនោះ ពុំអាចរកបាននៅមុនពេលការចាប់ផ្តើមជំនុំជម្រះ។

## III. ឧទ្ទិករណ៍

៧. បញ្ជើឯកសារនៅក្នុងឧបសម្ព័ន្ធ **ក** រួមបញ្ចូលទាំងឯកសារដែលមាននៅក្នុងសំណុំរឿងរួចហើយ និងឯកសារដែលមិនទាន់មាននៅក្នុងសំណុំរឿង[3]។ មេធាវីការពារក្ដីយល់ឃើញថាឯកសារដែលមានក្នុងសំណុំរឿងរួចហើយគឺអាចទទួលយកបាន អនុលោមតាមវិធាន៨៧(៣) ឬ ជាជម្រើសមួយផ្សេងទៀត អនុលោមតាមវិធាន៨៧(៤)។ មេធាវីការពារក្ដីយល់ឃើញថា ឯកសារដែលមិនទាន់មានក្នុងសំណុំរឿងអាចទទួលយកបាន អនុលោមតាមវិធាន៨៧(៤)។

### ក.វិធាន៨៧(៤) អនុវត្តចំពោះតែភស្តុតាងដែលមិនទាន់មានក្នុងសំណុំរឿងតែប៉ុណ្ណោះ

៨. វិធាន៨៧(២) និង (៣) បានពិពណ៌នាអំពីថ្នាក់ ឬប្រភេទនៃភស្តុតាងពីរផ្សេងគ្នាពោលគឺ ភស្តុតាងដែលមាននៅក្នុងសំណុំរឿង និងភស្តុតាង "ដែលបានដាក់នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង"។ អនុលោមតាមវិធាន៨៧(២) មានតែភស្តុតាងដែលបានដាក់នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូងប៉ុណ្ណោះ អាចត្រូវបានប្រើប្រាស់ជាមូលដ្ឋានក្នុងការធ្វើសេចក្ដីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង។

៩. វិធាន៨៧(៣) បានចែងពីដំណើរការដែលក្នុងនោះភស្តុតាង "ដែលមាននៅក្នុងសំណុំរឿង" បានក្លាយទៅជាភស្តុតាងដែលបានដាក់នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង។ យោងតាមវិធាន៨៧(៣) "ភស្តុតាងដែលមាននៅក្នុងសំណុំរឿងត្រូវបានចាត់ទុកថាបានលើកឡើងនៅចំពោះមុខអង្គជំនុំជម្រះ ឬភាគី បើសិនជាខ្លឹមសាររបស់វាត្រូវបានសង្ខេប ត្រូវបានអាន ឬ ត្រូវបានកំណត់បង្ហាញអត្តសញ្ញាណយ៉ាងសមស្របក្នុងសវនាការ"។ ដើម្បីធ្វើសេចក្ដីសម្រេច ថាតើត្រូវទទួលយកសំណើរបស់ភាគីសុំដាក់ភស្តុតាងបែបនេះនៅចំពោះមុខអង្គជំនុំជម្រះ ឬអត់នោះ អង្គជំនុំជម្រះត្រូវបានតម្រូវឲ្យពិចារណាការវាយតម្លៃដោយផ្អែកលើកត្តាចំនួនប្រាំ ដែលមានចែងក្នុងវិធាននេះ។

---

[3] ឧបសម្ព័ន្ធ ក បង្ហាញយ៉ាងច្បាស់អំពីភាពខុសគ្នារវាងឯកសារទាំងពីរប្រភេទ។

១០. វិធាន៨៧(៤) បង្ហាញនូវភស្តុតាងមួយប្រភេទបន្ថែមទៀតដែលខ្លួនហៅថា "ភស្តុតាងថ្មី"។ អនុលោមតាមវិធាន៨៧(៤) អង្គជំនុំជម្រះនឹងធ្វើសេចក្តីសម្រេចចំពោះការស្នើសុំនោះផ្អែកតាមខ្លឹមសារទាំងប្រាំដែលមានចែងក្នុងវិធាន៨៧(៣) ខាងលើ ប៉ុន្តែមានលក្ខខណ្ឌតម្រូវបន្ថែមមួយទៀតគឺ "សក្ខីកម្ម ឬភស្តុតាងដែលបានស្នើសុំនោះ ពុំអាចរកបាននៅមុនពេលចាប់ផ្តើមជំនុំជម្រះ"។

១១. ពាក្យថា "ភស្តុតាងថ្មី" មិនត្រូវបានផ្តល់និយមន័យ ឬត្រូវបានយកទៅប្រើនៅកន្លែងណាផ្សេងទៀតក្នុងវិធានផ្ទៃក្នុងឡើង ហើយជាទូទៅ វាអាចមានន័យផ្សេងគ្នាទៀត។ ឧទាហរណ៍ "ភស្តុតាងថ្មី" អាចមានន័យថាជាភស្តុតាងដែលមិនទាន់មានក្នុងសំណុំរឿង ឬភស្តុតាងដែលមាននៅក្នុងសំណុំរឿងប៉ុន្តែមិនទាន់បានដាក់នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង។ ប៉ុន្តែភស្តុតាងដែលមាននៅក្នុងសំណុំរឿងរួចហើយប៉ុន្តែមិនទាន់បានដាក់នៅចំពោះមុខអង្គជំនុំជម្រះត្រូវបានលើកឡើងក្នុងវិធាន៨៧(៣)។ គ្មានសេចក្តីយោងណាមួយត្រូវបានគេធ្វើឡើងក្នុងវិធាន៨៧ទៅកាន់ប្រភេទនៃភស្តុតាង ឬលក្ខខណ្ឌតម្រូវផ្នែករដ្ឋបាលដទៃទៀត អនុលោមតាមវិធានផ្ទៃក្នុងឡើយ។ ដូច្នេះ វាច្បាស់ណាស់ថាគោលបំណងតែមួយគត់របស់វិធាន៨៧(៤) គឺដើម្បីអនុញ្ញាតឱ្យមានការទទួលយកភស្តុតាងដែលមិនទាន់មាននៅក្នុងសំណុំរឿងចំពោះមុខអង្គជំនុំជម្រះសាលាដំបូង។ ភស្តុតាងដែលមាននៅក្នុងសំណុំរឿងរួចហើយគឺអាចទទួលយកបានអនុលោមតាមវិធាន៨៧(៣) ប៉ុណ្ណោះ។

១២. ដូច្នេះ លក្ខខណ្ឌតម្រូវដែលថា ភស្តុតាងដែលបានស្នើសុំនោះពុំអាចរកបាននៅមុនពេលចាប់ផ្តើមជំនុំជម្រះដូចដែលមានចែងក្នុងវិធាន៨៧(៤)នោះ មិនអាចយកមកអនុវត្តចំពោះឯកសារ A រហូតដល់ C នៅក្នុងឧបសម្ព័ន្ធ **ក** បានឡើយ ហើយឯកសារទាំងនេះគឺអាចទទួលយកបានស្របតាមការវាយតម្លៃដែលមានចែងក្នុងវិធាន៨៧(៣)[4] ។

## ខ.ឯកសារដែលមានក្នុងឧបសម្ព័ន្ធ ក គឺសុទ្ធមិនអាចរកបាននៅមុនពេលចាប់ផ្តើមជំនុំជម្រះស្របតាមខ្លឹមសារនៃវិធាន៨៧(៤)

[4] សូមមើលទំព័រខាងលើ, ករថាខណ្ឌ ១៨ ខាងក្រោម។

១៣. ទោះបីជាឯកសារ A រហូតដល់ C នៅក្នុងឧបសម្ព័ន្ធ **ក** មិនត្រូវទៅនឹងលក្ខខណ្ឌតម្រូវនៃវិធាន៨៧(៤) ក៏ដោយ ប៉ុន្តែវាពិតជាមិនអាចរកបាននៅមុនពេលចាប់ផ្តើមជំនុំជម្រះ ហើយវាអាចទទួលយកបានដោយឈរលើមូលដ្ឋាននេះ។ ឯកសារសេសសល់ដទៃទៀតក្នុងឧបសម្ព័ន្ធ **ក** ដែលមិនទាន់មាននៅក្នុងសំណុំរឿង ក៏ពុំអាចរកបាននៅមុនពេលចាប់ផ្តើមជំនុំជម្រះដែរ។

១៤. វិធាន៨៧(៤) ចែងយ៉ាងច្បាស់ថា ការទទួលយកភស្តុតាងថ្មីអាស្រ័យថា តើភស្តុតាងថ្មីហ្នឹង "អាចរកបាន"នៅមុនសវនាការដែរ ឬយ៉ាងណា ។ បន្ទាប់ពីបានស្រាវជ្រាវដោយយកចិត្តទុកដាក់ដោយប្រើពេលវេលាអស់យ៉ាងច្រើន និងបើទោះជាក្រុមមេធាវីការពារក្តីអាចប្រមូល និងកំណត់អត្តសញ្ញាណពីភាពពាក់ព័ន្ធរបស់ ឯកសារទាំងអស់ ដែលចុះក្នុងឧបសម្ព័ន្ធ **ក** នៅមុនសវនាការ ក៏មិនអាចបញ្ជាក់បានថាឯកសារ ទាំងនោះ "អាចរកបាន" ទៅតាមការចង់បាននៃវិធាន ៨៧(៤) បានដែរ ។ និយាយឲ្យចំទៅ ឯកសារសឹងតែទាំងអស់ គឺភាគីអាចរកបាននៅពេលណាមួយ ។ អង្គជំនុំជម្រះមិនគួរដាក់និយមន័យនៃភាពអាចរកបាន ដែលតម្រូវឲ្យភាគីនីមួយៗត្រៀមរៀបចំការពិនិត្យពេញលេញទៅលើសាក្សីសក្តានុពលប្រហែលមួយពាន់នាក់នៅមុនសវនាការនោះទេ[5]។

១៥. លក្ខខណ្ឌដែលតម្រូវដោយវិធាន ៨៧(៤) អាចថា តើភស្តុតាងត្រូវតែបានបង្ហាញនៅពេលវេលាសមស្របនៅចន្លោះពេលណាមួយនៃសវនាការដែរ ឬយ៉ាងណា ។ ភាគីមិនអាចដាក់ភស្តុតាងថ្មី នៅចុងពេលនៃសវនាការ ដែលភាគីដទៃទៀតមិនមានពេលវេលាគ្រប់គ្រាន់ដើម្បីត្រួតពិនិត្យ និងដើម្បីឲ្យសាក្សីដទៃអាចផ្តល់សក្ខីកម្មដែលអាចបញ្ជាក់តម្លៃបាន ។

១៦. ការបកស្រាយនៃលក្ខខណ្ឌតម្រូវនៃការទទួលយកភស្តុតាងក្រោមវិធាន ៨៧(៤) គឺសមស្របបំផុតដោយសារមូលហេតុជាច្រើន ។ ជាបឋម វាសមស្របជាមួយអត្ថន័យរបស់វិធាននេះ ។

[5] តាមពិតទៅក្នុងស្វែងរកលក្ខណៈសមហេតុផលលើគោលជំហររបស់យើងខ្ញុំ បុគ្គលមួយរូបមិនគួរគិតតែពីការចំណាយពេលវេលា និងធនធាន ដែលចាំបាច់ក្នុងការកំណត់អត្តសញ្ញាណ និងវិភាគរាល់ព័ត៌មានពាក់ព័ន្ធទាំងអស់ទាក់ទងតែទៅនឹងសាក្សីរូបនេះ (David Chandler) ជាជាងការចំណាយពេលវេលាងការកំណត់អត្តសញ្ញាណ និងវិភាគរាល់ព័ត៌មានពាក់ព័ន្ធទាំងអស់ទាក់ទងនិងសាក្សីសក្តានុពលទាំងអស់។

នៅពេលណាភាគីមួយអាចកំណត់បានពីភាពពាក់ព័ន្ធរបស់ឯកសារ ជាមួយនឹងដំណើរនីតិវិធីជំនុំជម្រះ នោះវាក្លាយជាឯកសារដែលអាចរកបានដោយភាគីហ្នឹង *ជាចំណែកមួយនៃភស្តុតាង* ភាគីមួយអាចមាន*ឯកសាររាប់ពាន់*នៅដៃ ប៉ុន្តែបើពួកគេនៅមិនទាន់ស្គាល់តម្លៃជាភស្តុតាងនៃឯកសារទាំងនោះដូចដែលតម្រូវដោយវិធាន៨៧(៤) "ភស្តុតាងនៅតែមិនអាចរកបាន"ដដែល។ ទីពីរវាជាដំណោះស្រាយដែលគិតតែពីលទ្ធផល ដែលបង្កើតខ្លឹមសារជាសារធាតុដល់វិធាន ។ ដោយសារសឹងតែគ្រប់ឯកសារទាំងអស់ អាចរកបាន ហើយដូច្នេះការបកស្រាយក្នុងន័យចង្អៀតនៃវិធាននេះ នឹងនាំឱ្យគេយល់ថាភស្តុតាងថ្មីសឹងតែទាំងអស់ មិនអាចទទួលយកបាន និងនាំឱ្យមានការច្រានចោលអត្ថិភាពនៃវិធាននេះ ។ ទីបីវាការពារផលប្រយោជន៍ពិតៗដោយមិនចាំបាច់ដាក់បន្ទុកផ្នែករដ្ឋបាលដោយបំពាន។ ការមិនទទួលយកភស្តុតាងដែលអាចរកឃើញតាំងពីដំណាក់កាលដំបូង ប៉ុន្តែត្រូវបានបង្ហាញយឺតពេល នឹងមិនបណ្តាលឱ្យភាគីណាមួយបាត់បង់សិទ្ធិឡើយ តែវាមិនបំរើឱ្យគោលបំណងពិតប្រាកដ ក្រៅតែពីការបង្កជាឧបសគ្គដល់តុលាការក្នុងការស្វែងរកការពិតប៉ុណ្ណោះ ។ និយាយឱ្យសាមញ្ញទៅ វានឹងមិនបំពេញបានទៅតាមការទាមទារដ៏ខែងរ៉ែងរបស់ភាគីដែរ ហើយហេតុដូច្នេះ វាក៏មិនមែនជាបំណងរបស់អ្នកពង្រាងវិធានផ្ទៃក្នុងដែរ[6]។ តែការដែលតម្រូវឱ្យភាគីបង្ហាញភស្តុតាងឱ្យបានឆាប់ ភ្លាមៗបន្ទាប់ពីភាគីបានដឹង ឬគួរតែបានដឹងពីតម្លៃរបស់ភស្តុតាង អង្គជំនុំជម្រះត្រូវធានាថា ពុំមាន

[6] ការបកស្រាយវិធានដែលជូនដោយអង្គជំនុំជម្រះ មិនបានគិតដល់ការពិតនៃសំណុំរឿងក្នុងដំណាក់កាលស៊ើបអង្កេត។ អង្គជំនុំសាលាដំបូងហាក់បីដូចជាចងមេធាវីការពារក្តីទៅនឹងបទដ្ឋាននៃការបំពេញការងារយ៉ាងយកចិត្តទុកដាក់ពិតប្រាកដ ដែលនឹងបង្ខំឱ្យមេធាវីការពារក្តី ធ្វើការស៊ើបអង្កេតមួយដែលស្របទៅនឹងការស៊ើបអង្កេតដែលធ្វើឡើងដោយ កសចស ដើម្បីធ្វើការប្រៀបធៀបគ្នានៅពេលបញ្ចប់ការស៊ើបអង្កេត និងដើម្បី ប្រៀបធៀបបញ្ជីនៃការបោះពុម្ពផ្សាយសំខាន់ៗ និងបន្ទាប់បន្សំណាមួយ ឬទាំងអស់ដែលទាក់ទងនឹងអំឡុងពេលកម្ពុជាប្រជាធិបតេយ្យ ក៏ដូចជាភស្តុតាងដើម ដែល ខ្លួន បាន រក ឃើញ។ តាមពិតទៅ ករណីនេះគឺមិនបានពិចារណាទៅដល់ការពិតដែលថាមេធាវីការពារក្តីបានជាប់រវល់ធ្វើការសិក្សា និងវិភាគភស្តុតាង ជាច្រើនដែលបានចងក្រងដោយ កសចស និងបានដាក់ទៅក្នុងសំណុំរឿងឡើយ ហើយសំខាន់ជាងនេះទៅទៀតនោះ មេធាវីការពារក្តីបានចំណាយពេលវេលា និងធានធានសេសល់របស់ខ្លួនភាគច្រើនលើការស្រាវជ្រាវ និងពង្រៀងពាក្យសុំទៅកាន់ កសចស ដើម្បីធ្វើការស៊ើបអង្កេតដោយខ្លួនឯង ដូចដែលបានចែងដោយវិធានផ្ទៃក្នុង។ សូមមើលឯកសារ **E-211** "សេចក្តីជូនដំណឹងទៅកាន់អង្គជំនុំជម្រះសាលាដំបូងទាក់ទងនឹងការស្រាវជ្រាវនៅ មជ្ឈមណ្ឌលឯកសារកម្ពុជា" ចុះថ្ងៃទី ១៩ ខែ មិថុនា ឆ្នាំ ២០១២, ឯកសារ ERN 00818156-00818163។

នរណាម្នាក់ត្រូវភ្ញាក់ផ្អើលដោយភស្តុតាង ហើយថាភស្តុតាងទាំងអស់ត្រូវបានវាយតម្លៃឱ្យបានពេញលេញ តាមតែអាចធ្វើទៅបាន ។ ទីបួន វាសមស្របទៅតាមវិធីសាស្ត្រទូទៅចំពោះច្បាប់ស្តីពីភស្តុតាង ទាំងវិធាននៃផ្ទៃក្នុង និងក្រមនីតិវិធីព្រហ្មទណ្ឌ ដែលបទប្បញ្ញត្តិទាំងពីរនេះបញ្ចៀសការទទួលយកភស្តុតាងលើសលុប តែផ្តោតទៅលើការថ្លឹងថ្លែងភស្តុតាងដែលដាក់នៅចំពោះមុខតុលាការ[7] ។

១៧. បញ្ជីឯកសារដែលដាក់នៅក្នុងឧបសម្ព័ន្ធ **ក** បានបំពេញបទដ្ឋាននេះ ។ ដោយសារតែ ជាភស្តុតាងនៃការវិភាគផ្ទាល់ដោយសាស្រ្តាចារ្យ Chandler ដូច្នេះវាជាភស្តុតាងតែមួយ និងមានតម្លៃ[8] ។ សម្រាប់មូលហេតុនេះ យើងខ្ញុំសូមដាក់ភស្តុតាងនេះ និងនៅពេលនេះនៃសវនាការ ។

១៨. ឯកសារទាំងអស់ដែលដាក់នៅក្នុងឧបសម្ព័ន្ធ **ក** បានបំពេញការធ្វើតេស្តទាំងប្រាំដែលមានចែងនៅក្នុងវិធាន ៨៧(៣) និងវិធាន ៨៧(៤) ។ ឯកសារទាំងនេះ ជាឯកសារពាក់ព័ន្ធពីព្រោះវាជាស្នាដៃនិពន្ធដោយសាស្ត្រាចារ្យ Chandler ហើយហេតុដូច្នេះ វាបានបង្កើតទស្សនៈរបស់គាត់ស្របតាមអ្វីដែលគាត់បានពិពណ៌នាពីពេលកន្លងមក។ ការថ្លែងពីលើកមុនរបស់សាស្ត្រាចារ្យ Chandler គឺពាក់ព័ន្ធយ៉ាងពិតប្រាកដដល់កិច្ចប្រឹងប្រែងរបស់មេធាវីការពារក្តី ដើម្បីជជីកសួរដេញដោលដល់សក្ខីកម្មរបស់គាត់។ ឯកសារដែលដាក់នៅក្នុងឧបសម្ព័ន្ធ **ក** មិនមែនជាឯកសារច្រំដែលនោះទេ ដោយសារតែពុំមានភស្តុតាងនៃការថ្លែងពីលើកមុនរបស់សាស្រាចារ្យ Chandler ដែលអាចបញ្ជាក់បានថាជាស្នាដៃ academic work ផ្ទាល់របស់គាត់ ។ សម្រាប់មូលហេតុស្រដៀងគ្នានេះ ឯកសារដែលដាក់នៅក្នុងឧបសម្ព័ន្ធ **ក** ក៏មិនមែនជាឯកសារមិនបានការ ឬមានបំណងពន្យារពេលនីតិវិធីដែរ តែជាភស្តុតាងសមស្របដែលបញ្ជាក់អង្គហេតុនានាដើម្បី (ជាពិសេសបញ្ជាក់ពីសាក្សីបាននិយាយពីលើកមុន)។ ពុំមានមូលហេតុណាដែល ឯកសារនៅក្នុងឧបសម្ព័ន្ធ **ក** ត្រូវបានបដិសេធដោយច្បាប់ឡើយ ។

---

[7] ក្រមនីតិវិធីព្រហ្មទណ្ឌព្រះរាជាណាចក្រកម្ពុជា មាត្រា ៣២១ “លើកលែងតែបទប្បញ្ញត្តិច្បាប់ផ្ទុយពីនេះ ភស្តុតាងក្នុងរឿងព្រហ្មទណ្ឌអាចជូនបានដោយសេរី”, វិធាន ៨៧(១)។

[8] សូមមើលកថាខណ្ឌ ១៨ ខាងក្រោម។

១៩. មេធាវីការពារក្តីស្នើដោយគោរពសុំដាក់ឯកសារទាំងអស់ដែលដាក់នៅក្នុងឧបសម្ព័ន្ធ **ក** នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង និងសូមប្រើប្រាស់ឯកសារទាំងនេះក្នុងអំឡុងពេលសួរដេញដោលសាស្ត្រាចារ្យ Chandler ។

**សហមេធាវីការពារក្តីលោក នួន ជា**

Jasper PAUW

Michel PESTMAN & Victor KOPPE